**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៣៨៨៥ ព.ណ.ន.ធ...

ថ្ងៃព្រហស្បតិ៍ ១០កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០២០

# សេចក្ដីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ អ្នកឧកញ៉ា លោកឧកញ៉ា លោក-លោកស្រី អ្នកនាង កញ្ញា ដែលជាផលិតករ ឬអ្នកនាំចេញទាំងអស់ឲ្យបានជ្រាបថា៖ ក្រសួងពាណិជ្ជកម្មអន្តរជាតិអង់គ្លេស បានជូនព័ត៌មានអំពីការផ្ដល់ការអនុគ្រោះពន្ធ (UK's Generalized Scheme of Preferences) ដល់បណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ដែលរួមមានប្រទេសអភិវឌ្ឍន៍តិចតួចផងដែរ (Least Developed Countries Framework)។ ដើម្បីទទួលបាននូវការអនុគ្រោះពន្ធពីចក្រភពអង់គ្លេស និងអនុលោមតាមប្រកាសលេខ ៣១៩៨ ពណ.ខកល ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ ស្ដីពីនីតិវិធីនៃការស្នើសុំ និងការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់តាមប្រព័ន្ធស្វ័យប្រវត្តកម្មតាមរយៈគេហទំព័រ https://co.moc.gov.kh និងប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្ដីពីការផ្ដល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្មដែលស្ថិតជាធរមាន ផលិតករ ឬអ្នកនាំចេញទាំងអស់ត្រូវធ្វើការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ អេ(CO FORM A) ដើម្បីបញ្ជាក់នូវដើមកំណើតទំនិញរបស់ខ្លួនដែលនឹងត្រូវធ្វើការនាំចេញទៅកាន់ចក្រភពអង់គ្លេសដោយរួចពន្ធ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ ខាងមុខនេះតទៅ។

សូមទំនាក់ទំនងដើម្បីទទួលបានព័ត៌មានបន្ថែម៖

១-លោក អ៊ុន ចាន់ថា ប្រធាននាយកដ្ឋាននាំចេញ នាំចូល ក្រសួងពាណិជ្ជកម្ម
ទូរស័ព្ទលេខ: ០១២ ៨៣៣ ៣៩៧ សារអេឡិកត្រូនិក: unchantha2017@gmail.com

២-លោក ស៊ី បាទិត្យ អនុប្រធាននាយកដ្ឋាននាំចេញ នាំចូល ក្រសួងពាណិជ្ជកម្ម
ទូរស័ព្ទលេខ: ០១២ ៩៤៨ ៤៨៤ សារអេឡិកត្រូនិក: batithsy@yahoo.com

៣-លោកស្រី កែ បូណា ប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញ នាំចូល ក្រសួងពាណិជ្ជកម្ម
ទូរស័ព្ទលេខ: ០១២ ៩៦៩ ៦៧៦ សារអេឡិកត្រូនិក: ke_bona@yahoo.com
ឬសារអេឡិកត្រូនិក: exportimportdept@moc.gov.kh

៤-លោកស្រី ម៉ក់ ច័ន្ទសុវណ្ណវល័ក្ខ អនុប្រធានការិយាល័យ នៃនាយកដ្ឋាននាំចេញ នាំចូល ក្រសួងពាណិជ្ជកម្ម
ទូរស័ព្ទលេខ: ០១២ ៦៩២ ០៨៨ សារអេឡិកត្រូនិក: makchansovanvoleak@yahoo.com

អាស្រ័យហេតុនេះ សូមផលិតករ ឬអ្នកនាំចេញទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២១ តទៅ។

**សូមអរគុណ!**